ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៣១.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួល មាត្រា៦ថ្មី នៃអនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៩ និងមាត្រា១០ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ និង មាត្រា៧ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើត ទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៩ និងមាត្រា១០ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**មាត្រាមួយ.**_

មាត្រា៦ថ្មី នៃអនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៩ និងមាត្រា១០ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នា២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ និង មាត្រា៧ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ ត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា៦ ថ្មី** (ពីរ)._

ទូរគមនាគមន៍កម្ពុជាត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងពេញលេញ ដើម្បីបំពេញការងារក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ និងលក្ខន្តិកៈរបស់ខ្លួន។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ០១រូប | ជាប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | ជាសមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | ជាសមាជិក |
| - តំណាងក្រសួងការពារជាតិ | ០១រូប | ជាសមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ០១រូប | ជាសមាជិក |
| - អគ្គនាយក **ទ.ក**. | ០១រូប | ជាសមាជិក |
| - តំណាងនិយោជិតរបស់ **ទ.ក**. | ០១រូប | ជាសមាជិក។ |

ក្នុងករណីតំណែងអគ្គនាយកនៅទំនេរ អគ្គនាយកស្តីទី **ទ.ក**. មានសិទ្ធិ និងបុព្វសិទ្ធិដូចអគ្គនាយក **ទ.ក**. ដែរ ។

**មាត្រា៧ ថ្មី.**_

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ៥ (ប្រាំ)ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី៦៥ (ហុកសិបប្រាំ)ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្រ្ត ឬនីតិសាស្រ្ត ដែលមានសញ្ជាតិខ្មែរ និងមិនដែលត្រូវផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ (បី)ឆ្នាំ។ អាណត្តិនេះ អាចបញ្ចប់ ឬអាចបន្តទៀតបានដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ឬអង្គភាពដែលខ្លួនតំណាងឲ្យ។

តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិតរបស់ **ទ.ក**.។

**មាត្រាពីរ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រាបី._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មីនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ